**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

អនុគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
ជូនមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្នាក់ដឹកនាំ
អង្គការវិជ្ជាជីវៈ កម្មករនិយោជិតតាមរោងចក្រ សហគ្រាស និងកម្មករ
សេដ្ឋកិច្ចក្រៅប្រព័ន្ធ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ

អនុគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ សូមជម្រាបជូន សាធារណជន អំពីលទ្ធផលការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១ ដោយថ្ងៃនេះ អនុគណៈកម្មការចំពោះកិច្ចបានបើកទីតាំងចាក់វ៉ាក់សាំងចំនួន ៤ទីតាំងបន្ថែម សរុបទាំងអស់ចំនួន ៧ទីតាំង ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**ក-លទ្ធផលក្នុងថ្ងៃទី៩ ខែមេសា**

- អ្នកស្ម័គ្រចិត្តចាក់វ៉ាក់សាំងសរុបចំនួន ៩ ៣៩៩នាក់ (បរទេសចំនួន ៥៥៥នាក់)
- ចាក់បានចំនួន ៨ ៩៨៤នាក់ (បរទេសចំនួន ៥៣៥នាក់)
- គ្រូពេទ្យមិនអនុញ្ញាតឱ្យចាក់ចំនួន ៤១៥នាក់ (បរទេសចំនួន ២០នាក់)។

**ខ-លទ្ធផលគិតត្រឹមថ្ងៃនេះ**

- អ្នកស្ម័គ្រចិត្តចាក់វ៉ាក់សាំងសរុបចំនួន ១៨ ៥១៨នាក់ (បរទេសចំនួន ៩០៣នាក់)
- ចាក់បានចំនួន ១៧ ៨៦២នាក់ (បរទេសចំនួន ៨៨៣នាក់)
- គ្រូពេទ្យមិនអនុញ្ញាតឱ្យចាក់ចំនួន ៦៥៦នាក់ (បរទេសចំនួន ២០នាក់)។

អនុគណៈកម្មការចំពោះកិច្ច នឹងបន្តរៀបចំទីតាំងចាក់វ៉ាក់សាំងជូនបងប្អូនកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស ជាបន្តបន្ទាប់ទៀត។

អាស្រ័យហេតុនេះ សូម សាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១